# សិលាចារឹកគោកប្រដាក K.៨៧៨

គោកប្រដាក ជាទួលប្រាសាទមួយស្ថិតនៅក្នុងភូមិអូរញែរ ឃុំបឹងព្រីង ស្រុកថ្មគោល ខេត្តបាត់ដំបង ពោលគឺស្ថិតនៅក្បែរព្រំប្រទល់ខេត្តបាត់ដំបង និងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។ ទីនេះមានឈ្មោះហៅផ្សេងទៀតដូចជា គុកប្រដាក (Kŭk Pradak) គោកបណ្ដាក់ និងឃូប្រដាក ដែលស្ថិតនៅចម្ងាយប្រមាណ៣,៥គីឡូម៉ែត្រ និរតីភ្នំតូច និង១គីឡូម៉ែត្រ ខាងជើងភូមិស្នួលកោង។[១] ទាក់ទងនឹងស្ថាននាមនេះ ហាក់ពុំមានឯកសារស្រាវជ្រាវកន្ទងមក បានលើកយកមកពន្យល់ឡើយ។ តាមរយៈផែនទីពីលើអាកាស ឃើញថានៅជ្រុងអាគ្នេយ៍គោកប្រដាក មានស្លាកស្នាមអាងស្តុកទឹកពីបុរាណមួយដែលមានបណ្ដោយប្រមាណ៨៦០ម៉ែត្រ និងទទឹង២៨០ម៉ែត្រ។ អាងស្ដុកទឹករបៀបនេះ មានឈ្មោះហៅប្លែកៗគ្នាទៅតាមតំបន់ដូចជា បារាយណ៍ ទន្លេអុំ និងប្រដាក ជាដើម។ ដូច្នេះស្ថាននាម គោកប្រដាក អាចទាក់ទងជាមួយអាងស្តុកទឹកនេះ ដូចគ្នានឹងករណីស្ថាននាមព្រះដាក់ នៅក្នុងស្រុកបន្ទាយស្រី ខេត្តសៀមរាបផងដែរ។[២] បច្ចុប្បន្ន អាងស្តុកទឹកនេះ បានក្លាយជាស្រែបង្កបង្កើនផលទៅហើយ។

ក្រៅពីសំណល់បុរាណវត្ថុមួយចំនួន គេធ្លាប់រកឃើញសិលាចារឹកមួយផ្ទាំង ដែលចារនៅលើមេទ្វារប្រាសាទខាងត្បូង មានចារឹកអក្សរចំនួន១៥បន្ទាត់ ចុះលេខបញ្ជីសារពើភណ្ឌសិលាចារឹក K.៨៧៨។ ដ្បិតតែសិលាចារឹកនេះ ក្រុមអ្នកស្រាវជ្រាវរបស់សាលាបារាំងចុងបូព៌ាប្រទេស (EFEO) បានផ្តិតសំណៅតាំងពីឆ្នាំ១៩៣៧មកក្តី រហូតមកដល់ឆ្នាំ១៩៥៣ ទើបលោកសាស្ត្រាចារ្យ ហ្សក សឺដែស ចុះផ្សាយអត្ថបទសិលាចារឹកនេះ នៅក្នុងសៀវភៅសិលាចារឹកនៃប្រទេសកម្ពុជា (IC) ក្បាលទី៥ របស់លោក។[៣] បន្ទាប់មក លោកសាស្ត្រាចារ្យ ហ្វីលីព ចេណ្ណឺរ ក៏បានសិក្សានៅក្នុងស្នាដៃរបស់លោក Part xml, № 9 និងចុះផ្សាយក្នុងគេហទំព័រ http://sealang.net/ok/corpus.htm។[៤]

---

[១] https://cisark.mcfa.gov.kh/core/showsite.php?id=4878

[២] សូមអានបន្ថែម៖ https://bit.ly/3iqbzlZ

[៣] Coedes 1953: 88-90។

[៤] សូមជ្រើសយកលេខ K.878។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

សិលាចារឹកនេះ មានចុះកាលបរិច្ឆេទនៅមហាសករាជឆ្នាំ៨១៨ (គ.ស.៨៩៦) និង មហាសករាជឆ្នាំ៨២០ (គ.ស.៨៩៨) ដែលស្ថិតនៅក្នុងរាជ្យព្រះបាទស្រីយសោវម៌្មទេវទី១ (គ.ស.៨៨៩-៩១០)។ ប៉ុន្តែតាមទម្រង់អក្សរដែលចារ អាចសង្កេតបានថាជាអក្សរនៅចន្លោះរវាងចុងស.វ.ទី១០ និងដើមស.វ.ទី១១ ទៅវិញទេ។ ដូច្នេះមានន័យថា អត្ថបទនេះជាអត្ថបទចាររំលឹកពីព្រឹត្តិការណ៍ ដែលកើតឡើងតាំងពីរាជ្យរបស់ព្រះបាទស្រីយសោវម៌្មទេវទី១ នាចុងសតវត្សទី៩មកម្ល៉េះ។

អត្ថបទនេះចាប់ផ្ដើមរំលឹកកាលពីឆ្នាំ៨៩៦ នាពេលដែលធ្វើបុណ្យឆ្លងប្រាសាទស្រីយសោធរេស្រីសទ្ធួជ ម្រតាញខ្លោញរុទ្របានថ្វាយតង្វាយក្នុងព្រះបរមនាមព្រះបាទស្រីយសោវម៌្មទេវទី១ ចំពោះប្រាសាទ និងថ្វាយតង្វាយទាំងនោះ ដែលមានដូចជាស្រែនិងខ្ញុំបម្រើ ដល់ប្រាសាទព្រះកម្តែងអញស្រីរុទ្រស្វាមីចាត់ចែងគ្រប់គ្រង។ នៅឆ្នាំ៨៩៨ ម្រតាញខ្លោញរុទ្របានទូលសុំព្រៃនិងដីទំពួននៅខេត្តបូព៌ាទិស ថ្វាយដល់ព្រះកម្តែងស្រីរុទ្រស្វាមី។ ព្រះមហាក្សត្រត្រាស់បង្គាប់ឱ្យម្រតាញស្រិវិក្រមាយុធ ចុះទៅជណ្ដឹងអ្នកស្រុកអំពីទំហំដីនោះ ដោយបោះបង្គោលព្រំដី។ ម្រតាញខ្លោញរុទ្រក៏បានថ្វាយតង្វាយមានស្វា១ស្នែងដូង២ និងសំពត់ស២ ដល់ប្រាសាទព្រះកម្តែងស្រីយសោធរេស្រីសទ្ធួជ ផងដែរ។

នៅផ្នែកខាងចុងបញ្ចប់ គឺជាការបញ្ជាក់ពីការងាររបស់ក្រុមអ្នកបម្រើដែលត្រូវធ្វើ និងពាក្យផ្ដាសាដល់នរណាដែលពុំធ្វើតាមរណ្ដាប់បូជាដែលបានរៀបចំនោះ ត្រូវធ្លាក់ទៅនរកទាំង៧សន្តាន ដរាបណាព្រះចន្ទនិងព្រះអាទិត្យនៅតែគង់នៅ។

លោក ហ្សក សឺដែស បានចោទជាសំណួរមន្ទិលសង្ស័យ ដោយមិនប្រាកដថា ប្រាសាទព្រះកម្តែងស្រីយសោធរេស្រីសទ្ធួជ និងប្រាសាទព្រះកម្តែងអញស្រីរុទ្រស្វាមី ជាប្រាសាទដែលមានទីតាំងនៅផ្សេងពីគ្នា ឬនៅទីតាំងតែមួយ តែមានក្ដីឬប្រាង្គពីរ។ គួរបញ្ជាក់ផងដែរថា ពាក្យ «ស្រីសទ្ធួជ» មានន័យថា (ទេព)ដែលមានគោឧសភជាសម្គាល់ គឺជាព្រះនាមមួយបែបទៀតរបស់ព្រះឥសូរ ដូចនាម រុទ្រស្វាមី។

## ១- អត្ថបទសិលាចារឹកជាអក្សរខ្មែរទំនើប

១- ៨១៨គកនុធ្វូលិវ្រះបាទគ្រីយគោវម៌្មទេវឱ[យ៉ា]ស្រេដេ[ង]៩គម្រ្យាងនុខ្ញុំ--សត្តប្រមានិ

អត្ថបទដោយៈ ហ៊ុន ឈុនតេង

២- ជេង៑តពញ៑ទក្សីណា[5]ម្រតាញ៑ខ្ញោញ៑រុទ្រនាឆ្នោង៑ប្រាសាទវ្រះកម្រតេង៑អញ៑ត្រីយគោ

៣- ធរវ្ម្មទ្វជជ្វន្តវ្រះកម្រតេង៑អញ៑ត្រីរុទ្រស្វាមិតបុន្យម្រតាញ៑ខ្ញោញ៑រុទ្រៈយោលំវិនាវា

៤- (យន)យោជេនិយោគីខាគក្តី[6]យោកនិហិៈតៃកន្ទេង៑តៃឆ្នំតៃកទ្រតៃនៃតៃកំមហិតៃសំអបិ

៥- តៃបំនង៑តៃប្រោ្វាតតៃកំរ្វៅ១៨២០នុម្រតាញ៑ខ្ញោញ៑រុទ្រស្វំប្រសាទវ្រៃភូមិតំរោនប្រមានិប្វ

៦- វ្ទិគឱយិតវ្រះកម្រតេង៑ត្រីរុទ្រស្វាមិៈវ្រះអាជ្ញាប្រេម្រតាញ៑ត្រីវីក្រមា[7]យុធវ្យា

៧- បារនាទោទៅឱយិគបតអនក្តស្រុកិប្វានិតោយិតង៑ត្យង៑អំម្រុង៑ភូមិតំរោនិសង្គោលិ

៨- ឱយ្តវ្រះកំម្រតេង៑អញ៑រុទ្រស្វាមិៈគោលិតិប្វូវ៌ប្រសបិ[8]លិំ[9]បេង៑ៈគោលិតិទក្សិណប្រសបិ

៩- ត្រវាង៑វ្រាហ្មណគោលិតិបគ្និមល្វោះតផ្វូតទិង៑គោលិតិឧត្តរលោះតផ្វូ[10]ប្រសបិសាធុបល្វីយ[11]

១០- យោលំវិរិនយោ[12]យោចន្ទ្រវលយោវន្ទនិយោមន្ទាតៃលង្គាយិតៃវិចិត្រតៃគោលិតៃតិប៌តៃមធុវា

១១- កល្បនាម្រតាញ៑ខ្ញោញ៑រុទ្រតវ្រះកំម្រតេង៑អញ៑ត្រីយគោធរវ្ម្មទ្វជៈស្វាបេង៑ម្វាយិតោង៑វ្យ

---

[5] សីដេស និង៑ចេណ្ណឹរ អានថា ទក្សិណា តែតាមការពិនិត្យក្នុង៑សំណៅផ្តិតគឺ ស្រៈ ី។

[6] សីដេស និង៑ចេណ្ណឹរ អានថា គិខាគក្តិ, តែតាមការពិនិត្យសំណៅផ្តិតគឺ ស្រៈ ី ទាំង៑ពីរ។

[7] សីដេស និង៑ចេណ្ណឹរ អានថា វិក្រមាយុធ, តែតាមការពិនិត្យក្នុង៑សំណៅផ្តិតគឺ ស្រៈ ី។

[8] សីដេស និង៑ចេណ្ណឹរ អានថា ប្រសាបិ, តែតាមការពិនិត្យក្នុង៑សំណៅផ្តិតគឺមិនមាន ស្រៈ ា ទេ។

[9] សីដេស និង៑ចេណ្ណឹរ មិនអានពាក្យ លិំ ទេ, តែតាមការពិនិត្យក្នុង៑សំណៅផ្តិតគឺ លិំបេង៑។

[10] ស្រៈ ូ ចារទំហំតូច ស្រដៀង៑នឹង៑ស្រៈ ុ។

[11] សីដេស និង៑ចេណ្ណឹរ អានថា បល្វិយ, តែតាមការពិនិត្យក្នុង៑សំណៅផ្តិតគឺ ស្រៈ ី។

[12] សីដេស និង៑ចេណ្ណឹរ អានថា លំវិរិវាៈ, តែតាមការពិនិត្យក្នុង៑សំណៅផ្តិតគឺ លំវិរិន។

អត្ថបទដោយៈ ហ៊ុន ឈុនតេង៑

១២- រិ(វាត់)សោ[១៣] វ្យរវ្ងំអាច្ដិហៅអនក់ប្រះ(ប៉ិ)ប្រេទៃតិលេងផ្វន់ទីក៌[១៤]នុឱយិស្វា មហានវមីគុសិអនិក៌កទ្រ

១៣- បត្តនប្រមានិដេង្នំឃោកនិសិបិឃោកំព្រៅឃោកំបុរិតៃជានុគ្រីយតៃកទ្រតៃ បពោងនេះគិតឱយិស្ទុក[១៥]

១៤- វិនៅម្វាយិសហស្រតគិមាយគិនាស្វតន្ត្រអនិក៌ប្រះតព្រាហ្មណាចាយ៌្យតស្តាបវត្ត៌ មានៈនៅអន

១៥- ក្តវ្ងំថ្ងៃពោះកល្បនានេះគេទៅតនរកសប្តបុរុបាន្តរយោវតិចន្ទ្រាទិត្យមាន៙

## ២- អត្ថបទប្រែសម្រួលជាភាសាខ្មែរទំនើប

(១-៥) មហាសករាជឆ្នាំ៨១៨ នូវធូលីព្រះបាទស្រីយសោវម៌្មទេវ(ទី១) (ស្តេចប្រទាន) ស្រែ៥ជើង(ឯ)គម្ប្រាង ខ្ញុំបម្រើ-- (នៅ)ប្រមាណជើងត្រាញ់ (ជា)តង្វាយរបស់ម្រតាញរុទ្រនា(ឱកាស)ធ្វងប្រាសាទព្រះគម្តែងអញស្រីយសោធរេ្វីមទ្វជ (និង)ថ្វាយ(តង្វាយទាំងនេះ) ដល់(ប្រាសាទ)ព្រះគម្តែងអញស្រីរុទ្រស្វាមី ដ៏ជាបុណ្យរបស់ម្រតាញខ្លោញរុទ្រ។ (ខ្ញុំបម្រើមាន) ឃោលំវិនាពយន ឃោជេន ឃោសិខាសក្តិ ឃោកន្ធិ តៃកន្ទេង តៃឆ្ទើម តៃកទ្រ តៃនៃ តៃកំមះ តៃសំអប់ តៃបំនង តៃប្រួត តៃកំព្រៅ។

(៥-១២) មហាសករាជឆ្នាំ៨២០ នូវម្រតាញខ្លោញរុទ្រសុំព្រះរាជទានព្រៃ(និង)ដីទំពួន(នៅ)ខេត្ត/តំបន់បូព៌ាទិស ឱ្យដល់ព្រះគម្តែងស្រីរុទ្រស្វាមី។ (ព្រះបាទស្រីយសោវម៌្មទេវទី១ចេញ)ព្រះអាជ្ញា(ត្រាស់)ប្រើម្រតាញស្រីវិក្រមាយុធ(ជា)មន្ត្រីថ្នាក់ទី២ ទៅឱ្យអ្នកស្រុកទាំងបួនស្បថនិងជណ្តឹងសួរពីទំហំដីទំពួន ដើម្បីសង់បង្គោល(ព្រំដី)ឱ្យដល់ព្រះគម្តែងអញរុទ្រស្វាមី។ បង្គោលដីនៅទិសខាងកើតប្រសព្វនឹងរលំបេង បង្គោលដីខាងត្បូងប្រសព្វនឹងត្រពាំងព្រាហ្មណ៍ បង្គោលដីខាងលិចដល់ផ្លូវទទឹង បង្គោលដីខាងជើងដល់ផ្លូវប្រសព្វនឹងសាធុបល្វីយ។ (អ្នកបម្រើនៅទីនោះមាន)ឃោលំវិរិនយោ ឃោចន្ទ្រវល ឃោវន្ទន ឃោមន្ទា តៃលង្គាយ តៃវិចិត្រ តៃគោលិ តៃតិថ៌ តៃមធុរា។ តង្វាយរបស់ម្រតាញខ្លោញរុទ្រ ថ្វាយ

---

[១៣] សីដេស និងចេណ្ណឹរ មិនបានអានពាក្យ (វាត់)សោ ទេ។

[១៤] សីដេស និងចេណ្ណឹរ អានថា ទិក៌, តែតាមការពិនិត្យក្នុងសំណៅផ្តិតគឺ ស្រៈ ី។

[១៥] សីដេស និងចេណ្ណឹរ អានថា ស្វក, តែតាមការពិនិត្យក្នុងសំណៅផ្តិតគឺ ស្រៈ ឲ ពុំមែនជាជើង ញ ទេ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ចំពោះប្រាសាទព្រះគម្តែងអញស្រីយសោធរវ្រើសទ្ធជ (មាន)ស្វា១ចែង(/ស្នែង) ដូង២ សំពត់ (?)ស២។

(១២-១៥) ពុំអាចហៅអ្នកបម្រើព្រះដើម្បីប្រើ(ធ្វើការ)ដទៃ(ផ្សេងទៀយ) ឱ្យ(ប្រើ)ជូនទឹកនិងឱ្យស្វាមហានវមីតែប៉ុណ្ណោះ។ អ្នក(បម្រើននៅ)កទ្រូបត្តន(ឯ)ខេត្ត/តំបន់ជើងភ្នំ(មាន) ឃោកន្សិប ឃោកំព្រៅ ឃោកំបោរ តែជានុស្រី តែកទ្រ (និង)តែបពោង (ទាំងប៉ុន្មាននាក់) នេះ គឺអ្នកថ្វាយស្វឹកឡៅ១០០០(សន្ទឹក)នៅខែមាឃ គឺជាអ្នកបម្រើព្រះរបស់ព្រាហ្មណ៍និងអាចារ្យដែលនៅចាំស្តាប់ព័ត៌មាន។ នូវអ្នកពុំធ្វើដូចរណ្តាប់បូជានេះ អ្នកនោះធ្លាក់ទៅនរក៧សន្តាន ដរាបណាព្រះចន្ទ្រនិងព្រះអាទិត្យនៅតែមាន៕

## ឯកសារពិគ្រោះ


CISARK

https://cisark.mcfa.gov.kh/core/showsite.php?id=4878

Cœdès, G.

1953. Piédroit de Pràsàt Kŭk Pradak (K. 878) in *Inscriptions du Cambodge*, Vol. 5. Paris.

Jenner, P.

Inscription of Pràsàt Kŭk Pradak in *Part* xml, № 9. http://sealang.net/ok/corpus.htm


អត្ថបទដោយ៖ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព




Imagery ©2022 Maxar Technologies, CNES / Airbus, Imagery ©2022 CNES / Airbus, Maxar Technologies, Map data ©2022 100 m

ផែនទីតំបន់គោកប្រដាកពីលើអាកាស (រូបថត៖ Google Maps 2022)



សំណៅផ្តិតសិលាចារឹកគោកប្រដាក (រូបថត EFEO_ CAM17141-1)

អត្ថបទដោយៈ ហ៊ិន ឈុនតេង